# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៧០៦៨ សរ.អត

មកដល់ អគ.បេ
ថ្ងៃទី 29 ខែ 12 ឆ្នាំ 09
ម៉ោង 10:50 ចុះបញ្ជីលេខ 731

មកដល់ក្រសួង អ.យ.ក
ថ្ងៃទី 29 ខែ 12 ឆ្នាំ 2009
ម៉ោង........នាទី ចុះលេខ 394

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩

## សូមជម្រាបជូន

## ឯកឧត្តម លោកជំទាវ អគ្គនាយករដ្ឋបាល

## គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និងស្ថាប័នរដ្ឋ

**កម្មវត្ថុ** : ករណីលិខិតបទដ្ឋានគតិយុត្ត ដែលស្នើឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ជា Soft Copy ។

**យោង** : -លិខិតលេខ ៨២៧ សជណ.អគ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី
-សារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ជ្រាបថា: ដើម្បីឱ្យមានលក្ខណៈងាយស្រួល និងឯកភាពគ្នាលើពុម្ពអក្សរ (Font) Computer នោះអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលស្នើសុំរាល់លិខិតបទដ្ឋានគតិយុត្តទាំងអស់ ដែលត្រូវស្នើសុំដាក់ប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី សូមវាយអក្សរខ្មែរយូនីកូដ (Khmer-Unicode) វិញដើម្បីឱ្យដំណើរការនៃការផ្លាស់ប្តូរពុម្ពអក្សរ (Font) នេះមានភាពរលូនឆាប់រហ័ស និងអនុវត្តឱ្យបានស៊ីសង្វាក់គ្នា ។ ចំពោះការផ្លាស់ប្តូរវាយពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) នេះ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលសូមកំណត់រយៈពេលឱ្យតែ៦០ថ្ងៃប៉ុណ្ណោះ សម្រាប់ក្រសួង-ស្ថាប័នទាំងអស់ធ្វើការរៀបចំ គិតចាប់ពីថ្ងៃនៃការជូនដំណឹងនេះ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ មេត្តាសហការចំពោះការផ្លាស់ប្តូរពុម្ពអក្សរ (Font) ទាំងអស់ឱ្យទៅជាពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode)វិញ ក្នុងករណីមានការលំបាកលើបញ្ហាបច្ចេកទេសសូមធ្វើការទំនាក់ទំនងជាមួយ NiDA ដើម្បីជួយសម្រួល។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

**ទីប្រឹក្សារាជរដ្ឋាភិបាល** និងជា
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

ចម្លងជូន:
- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (NiDA)
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- គ្រប់អាជ្ញាធរនិងអង្គភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ -កាលប្បវត្តិ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ទូរសារ: ០២៣ ២១២ ៩៣៤ ទូរស័ព្ទ: ០១១ ៩៦០ ១៥៩/ ០១២ ៨២១ ៤៤១/ ០១២ ៤៥៦ ១៤៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ:** ០១ សរណន

# សារាចរណែនាំ
## ស្ដីពី
## ការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ (Khmer Unicode)

កន្លងមក អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA) បានបង្កើតនូវកម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដមួយ ដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់។

ទីស្ដីការគណៈរដ្ឋមន្ត្រី សូមធ្វើការណែនាំដល់គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរក្រោមឱវាទទីស្ដីការគណៈរដ្ឋមន្ត្រីទាំងអស់ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ ក្នុងការផលិត និងរៀបចំគ្រប់ឯកសាររដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តនានា សំដៅឲ្យមានការឯកភាពគ្នា និងជួយសម្រួលការងារនៅក្នុងក្របខ័ណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រីទាំងមូល។ ចំពោះកម្រងកម្មវិធីគំរូអក្សរខ្មែរយូនីកូដ និងរបៀបប្រើប្រាស់ សូមទាក់ទងជាមួយអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA)។

ទទួលបានសារាចរណែនាំនេះ ស្ថាប័ន អង្គភាព និងអាជ្ញាធរនានាក្រោមឱវាទទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវចាត់ចែងអនុវត្តជាកំហិតក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល:

- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរចំណុះទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*